(បកប្រែក្រៅផ្លូវការ)

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០២០

**ឯកឧត្តម ស៊ូហ្គា យ៉ូស៊ីហ៊ីដេ**
នាយករដ្ឋមន្ត្រីជប៉ុន
ទីក្រុងតូក្យូ

**ឯកឧត្តម**

តាងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយសូមសម្តែងការអបអរសាទរយ៉ាងកក់ក្តៅបំផុត ក្នុងឱកាសដែលឯក**ឧត្តម** ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីថ្មីរបស់ជប៉ុន បន្ទាប់ពីទទួលបានជ័យជំនះយ៉ាងភ្លូកទឹកភ្លូកដី ក្នុងការបោះឆ្នោតជាប្រធានដឹកនាំគណបក្សប្រជាធិបតេយ្យសេរី (LDP) កាលពីថ្ងៃទី១៤ កញ្ញា ២០២០។

ជ័យជំនះយ៉ាងត្រចះត្រចង់នេះ បានឆ្លុះបញ្ចាំងពីការគាំទ្រយ៉ាងមុតមាំរបស់សមាជិកគណបក្ស LDP ក៏ដូចជាទំនុកចិត្តរបស់ប្រជាជនជប៉ុនចំពោះទស្សនៈវិស័យគោលនយោបាយ និងភាពជាអ្នកដឹកនាំរបស់ឯក**ឧត្តម** ក្នុងការជំនះឱ្យបាននូវវិបត្តិកូវីដ-១៩ និងការស្តារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាការធានាឱ្យបាននូវអនាគតរបស់ប្រទេសជប៉ុនប្រកបដោយសន្តិភាព និងវិបុលភាព។

ខ្ញុំត្រៀមខ្លួនធ្វើការយ៉ាងជិតស្និទ្ធជាមួយឯក**ឧត្តម** ក្នុងគោលបំណងបន្តពង្រឹង និងលើកកម្ពស់ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិជិតស្និទ្ធរវាងកម្ពុជា និងជប៉ុនបន្ថែមទៀត ដើម្បីផលប្រយោជន៍ទៅវិញទៅមកសម្រាប់ប្រជាជននៃប្រទេសយើងទាំងពីរ ព្រមទាំងដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់ និងពិភពលោក។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំ និងសូមជូនពរ **ឯកឧត្តម** សូមប្រកបដោយសុខភាពល្អបរិបូណ៌ និងទទួលជោគជ័យនូវរាល់គ្រប់ភារកិច្ចដ៏ឧត្តុងឧត្តម។

ហ៊ុន សែន